**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ........✓...........ន. គ. ស .......

ថ្ងៃព្រហ.១២កើតខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ,ថ្ងៃទី ៨ ខែតុលាគ.ស.២០២៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំលឹកកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មក និយ័តករគណនេយ្យនិងសវនកម្មសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(**អ.ស.ហ.**) សូមជម្រាបជូន លោក លោកស្រី ជាម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យជ្រាបថា៖ កាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤នេះ មានសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យចំនួន១៤,៤៩១ បានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ(E-Filing System) តាមពេលកំណត់ និងមានសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យមួយចំនួនទៀតបានកំពុងស្នើសុំពន្យារពេលដើម្បីបញ្ចប់នីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ។ *ដោយឡែក មានសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យចំនួនប្រមាណ ៦,១០០ បានទទួលលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនបានអនុវត្តនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** នៅឡើយ។*

ក្នុងន័យនេះ **ន.គ.ស.** សូមក្រើនរំលឹកដល់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យដែលមិនទាន់បានបញ្ចប់នីតិវិធីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤មក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ (E-Filing System) ត្រូវរួសរាន់អនុវត្តកាតព្វកិច្ចនេះ ជៀសវាងការទទួលរងទោសទណ្ឌអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ចំពោះសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានបិទបញ្ចប់សកម្មភាពអាជីវកម្ម ឬប្រតិបត្តិការរបស់ខ្លួន ត្រូវដាក់លិខិតជូនដំណឹងបិទមក **ន.គ.ស.** ឱ្យបានមុនកាលបរិច្ឆេទផុតកំណត់ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ACAR & Enterprise

ដើម្បីទទួលបាន ឬសាកសួរព័ត៌មាន
អំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់ ន.គ.ស.